www.kidworship.kr

# ចំណងជើង៖ ការឆ្កាង



137Page

**Narration** នៅថ្ងៃមួយព្រះយេស៊ូបានយាងមកជាមួយនឹងពួកសិស្សដល់កន្លែងមួយឈ្មោះ
កេតសេម៉ានី។

**ព្រះយេស៊ូ** អ្នកត្រូវនៅទីនេះរង់ចាំមើល រហូតដល់ខ្ញុំត្រឡប់មកវិញ!

**Narration** បន្ទាប់ពីព្រះយេស៊ូមានព្រះបន្ទូលទៅពួកសិស្សហើយ
ព្រះអង្គយាងទៅមុខបន្តិចក្រាបព្រះភ័ក្ត្រដល់ដី ហើយអធិស្ឋានទូលអង្វរថា៖

**ព្រះយេស៊ូ** ឱបិតាអើយ! ព្រះអង្គអាចសំរេចគ្រប់កិច្ចការទាំងអស់បាន សូមដកពែងនៃទុក្ខលំបាកនេះ
ចេញឲ្យឆ្ងាយពីទូលបង្គំទៅ ប៉ុន្តែសូមកុំតាមបំណងចិត្តទូលបង្គំឡើយ
គឺសូមឲ្យបានសំរេចតាមព្រះហឫទ័យព្រះអង្គវិញ។

**Narration** នៅពេលដែលព្រះយេស៊ូបានអធិស្ឋាន
នោះមានទេវតាបានលេចមកឯទ្រង់ដើម្បីចម្រើនកំលាំងដល់ទ្រង់
បន្ទាប់មកទ្រង់បានយាងមករកពួកសិស្ស
ឃើញពួកគេកំពុងតែដេកលក់ព្រះអង្គបានមានព្រះបន្ទូលទៅកាន់គេថា៖

**ព្រះយេស៊ូ** អ្នករាល់គ្នាមិនស៊ូទ្រាំប្រុងស្មារតីជាមួយខ្ញុំ សូម្បីតែមួយម៉ោងក៏មិនបានដែរឬ។
ចូរប្រុងស្មារតី ហើយអធិស្ឋាន កុំឲ្យចាញ់ការល្បួងឡើយ។

............................................................



138Page

**Narration** មិនយូរប៉ុន្មាននៅពេលដែលព្រះយេស៊ូកំពុងតែមានព្រះបន្ទូលនៅឡើយ
ស្រាប់តែយូដាសជាសិស្សម្នាក់
ក្នុងចំណោមសិស្សទាំងដប់ពីរនាក់បានមកដល់ទាំងមានទាហានជាច្រើន កាន់ដាវ
កាន់ដំបងមកជាមួយផង។ យូដាសបានរកវិធីសាស្ត្រចូលទៅជិតពួកនាយកបូជាចារ្យ
និងពួកព្រឹទ្ធាចារ្យ ដើម្បីនាំខ្លួន និងក្បត់ព្រះយេស៊ូក្នុងតម្លៃប្រាក់សាមសិបស្លឹង។

**យូដាស** សូមចាប់បុរសដែលខ្ញុំថើប ដ្បិតគេនោះហើយជាព្រះយេស៊ូ!

**Narration** យូដាសបានថើបព្រះយេស៊ូ នៅពេលនោះហើយដែលពួកទាហានបានចាប់ព្រះយេស៊ូ។

............................................................



139Page

**Narration** ពួកនាយកបូជាចារ្យបានសួរសំនួរទៅព្រះយេស៊ូថា៖

**នាយកបូជាចារ្យ** តើអ្នកពិតជាបាននិយាយថា អ្នកគឺជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ពិតមែនឬទេ?

**ព្រះយេស៊ូ** ដូចលោកមានប្រសាសន៏មែនហើយ ខ្ញុំពិតជាបុត្ររបស់ព្រះជាម្ចាស់
ប៉ុន្តែខ្ញុំសូមបញ្ជាក់ប្រាប់អស់លោកថា
អំណើរតទៅអស់លោកនឹងឃើញបុត្រមនុស្សគង់នៅខាងស្តាំ ព្រះដ៏មានឫទ្ធានុភាព
ហើយនឹងយាងពីលើពពកក្នុងផ្ទៃមេឃ។

**Narration** នាយកបូជាចារ្យបានស្រែកដោយកំហឹងថា៖

**នាយកបូជាចារ្យ** ជននេះបានពោលពាក្យប្រមាថព្រះជាម្ចាស់ហើយ អ្នកនេះត្រូវមានទោសដល់ជីវិត។

**Narration** ចុងក្រោយលោកមហាបូជាចារ្យនិងអ្នកដឹកនាំនៃសាសន៍អ៊ីស្រាអែលបានសំរេចដាក់ទោស
សំឡាប់ព្រះយេស៊ូ។ បណ្តាជនបាននាំគ្នាស្តោះទឹកមាត់ដាក់ព្រះភ័ក្ត្រព្រះយេស៊ូ
ហើយអ្នកខ្លះបានវាយតប និងទះកំផ្លៀងព្រះអង្គផងដែរ។

---



140Page

**Narration** លុះព្រឹកឡើង ពួកនាយកបូជាចារ្យ, ព្រឹទ្ធាចារ្យ, អ្នកបង្រៀនខាងក្រិត្យវិន័យ
និងក្រុមប្រឹក្សាជាន់ខ្ពស់បានឲ្យគេចងព្រះយេស៊ូ និងនាំទ្រង់ទៅឯលោកពីឡាត។
ពួកគេបាននាំគ្នាចោទប្រកាន់ទៅព្រះយេស៊ូ ប៉ុន្តែព្រះអង្គពុំបានឆ្លើយតបអ្វីទាល់តែសោះ។
ទោះជាយ៉ាងណាក៏ដោយក៏លោកពីឡាត់បានដឹងថា ព្រះយេស៊ូទ្រង់គ្មានកំហុសឡើយ។
នៅថ្ងៃនោះ ជារៀងរាល់ឆ្នាំ ក្នុងឱកាសបុណ្យរំលង
លោកទេសាភិបាលតែងតែលែងអ្នកទោសម្នាក់តាមសំណូមពររបស់បណ្តាជន។
នោះលោកពីឡាតក៏សួរទៅបណ្តាជនថា៖

**ពីឡាត** តើអ្នករាល់គ្នាចង់ឲ្យខ្ញុំដោះលែងអ្នកណា ប៉ារ៉ាបាស់ ឬ យេស៊ូ?

**បណ្តាជន** បារ៉ាបាស! បារ៉ាបាស! បារ៉ាបាស បារ៉ាបាស!

**Narration** បារ៉ាបាស បានជាប់គុកដោយសារអំពើឃាតកម្ម។
ប៉ុន្តែហ្វូងមនុស្សបានស្រែកឲ្យដោះលែង បារ៉ាបាស ទៅវិញ។
ដោយសារលោកពីឡាតខ្លាចមានការធ្វើគុប្បកម្ម នោះលោកបានមានប្រសាសន៍ថា៖

**ពីឡាត** តាមតែអ្នកចង់ទៅចុះ! ប៉ុន្តែខ្ញុំគិតថាឈាមរបស់ម្នាក់នេះគឺគ្មានបាបទេ។
ដូច្នេះអ្នកគួរតែធ្វើវាដោយការទទួលខុសត្រូវ។

**Narration** ទីបំផុតលោកពីឡាតបានដោះលែង បារ៉ាបាស ហើយចាប់ព្រះយេស៊ូយកទៅឆ្កាង។

---



141Page

**Narration** គេបានដោះព្រះពស្ត្ររបស់ព្រះអង្គចេញ ហើយយកអាវធំដែលមានពណ៌
ក្រហមទុំមកបំពាក់ថ្វាយព្រះអង្គ។
គេយកបន្លាមកក្រងធ្វើជាភួងបំពាក់លើព្រះសិរសាព្រះអង្គនិងយកដើមត្រែងមកដាក់ក្នុង
ព្រះហស្តស្តាំឲ្យព្រះអង្គកាន់ រួចពួកគេនាំគ្នាលុតជង្គង់នៅមុខព្រះអង្គទាំងពោលថា៖

**ពួកទាហាន** ហេ!! សូមគោរពថ្វាយបង្គំស្តេចយូដា!

**Narration** ក្រោយពីបានជេប្រមាថមើលងាយព្រះអង្គរួចហើយ ពួកគេដោះអាវធំចេញយកព្រះពស្ត្រ
របស់ព្រះអង្គមកបំពាក់ថ្វាយព្រះអង្គវិញ រួចនាំគ្នាបណ្តើរព្រះអង្គយកទៅឆ្កាង។
ព្រះយេស៊ូត្រូវបានលីឈើឆ្កាងរបស់ទ្រង់ទៅឯកន្លែងមួយឈ្មោះថា គាល់កូថា។
ព្រះយេស៊ូត្រូវដួលជាច្រើនដងដោយសារទម្ងន់របស់ឈើឆ្កាងបានធ្លាក់ពីលើទ្រង់។

**ពួកទាហាន** ឆាប់ក្រោកឡើង! កុំចង់ឈប់ឲ្យសោះ!!

**Narration** ពេលគេនាំព្រះយេស៊ូចេញពីទីក្រុងបានបន្តិច គេបានជួបនឹងបុរសម្នាក់ឈ្មោះ ស៊ីម៉ូន
ជាអ្នកស្រុកគីរេន ពួកទាហានបានបង្ខំឲ្យគាត់លីឈើឆ្កាងរបស់ព្រះយេស៊ូ។

---



142Page

**Narration** ទីបំផុតពួកទាហានបាននាំព្រះយេស៊ូមកដល់ គាល់កូថា។
ពួកគេបានដោះយកសំល្បៀកបំពាក់របស់ព្រះអង្គចេញ រួចចាប់ទ្រង់យកទៅឆ្កាង
ដោយដំព្រះហស្តនិងព្រះបាទាទ្រង់ជាប់ទៅនឹងឈើឆ្កាងដោយ ដែកគោល។
ក្រោយពីឆ្កាងព្រះអង្គរួចហើយ
ពួកទាហានបានយកសំល្បៀកបំពាក់របស់ទ្រង់មកចាប់ឆ្នោតចែកគ្នា
រួចបានសរសេរប្រកាសប្រាប់ដាក់នៅលើព្រះសិរសារបស់ព្រះអង្គថា “
នេះហើយជាស្ដេចរបស់សាសនយូដា” ព្រះយេស៊ូបានមានព្រះបន្ទូលដោយភាពឈឺចាប់។

**ព្រះយេស៊ូ** ឱបិតានៃទូលបង្គំអើយ! សូមទ្រង់លើកលែងទោសដល់ពួកគេផង
ដ្បិតពួកគេមិនដឹងថាពួកគេកំពុងតែធ្វើអ្វីឡើយ។

.................................................................................................................



143Page

**Narration** បន្ទាប់មកផែនដីទាំងមូលប្រែជាងងឹតសូន្យ
នៅពេលដែលព្រះយេស៊ូបានស្រែកយំដោយសំលេងយ៉ាងខ្លាំង។

**ព្រះយេស៊ូ** ឱព្រះនៃទូលបង្គំ, ព្រះនៃទូលបង្គំអើយ
ហេតុអ្វីបានជាព្រះអង្គបោះបង់ចោលទូលបង្គំដូច្នេះ?

**Narration** ព្រះយេស៊ូទ្រង់ជ្រាបថាពេលវេលារបស់ព្រះអង្គ នៅលើផែនដីនេះត្រូវបានបញ្ចប់
ដូច្នេះពេលនោះព្រះអង្គបានមានព្រះបន្ទូលនូវអ្វីទាំងអស់នេះ។

**ព្រះយេស៊ូ** សូមឲ្យការនេះបានសំរេចទៅចុះ។



144Page

**Narration** ព្រះយេស៊ូបានឱនព្រះភ័ក្ត្ររបស់ទ្រង់ចុះ ហើយក៏ថ្វាយវិញ្ញាណទៅ។
នៅពេលនោះវាំងននៅក្នុងព្រះវិហារក៏បានរហែកជាពីរ តាំងពីលើរហូតដល់ក្រោម
ហើយផ្ទៃរក៏បើកចំហរឡើង។
ព្រះយេស៊ូពិតជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ដែលទ្រង់បានសុគតសំរាប់អំពើបាបរបស់
មនុស្សនៅលើផែនដីពិតប្រាកដមែន។